# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៣. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រី រាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៥

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៥៦ ស្តីពីការកំណត់ពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

# សម្រេច

**មាត្រា ១.-**

អនុញ្ញាតអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ បានឈប់សម្រាកការងារប្រចាំឆ្នាំ ២០០៥ តាមប្រតិទិន ដូចខាងក្រោម :

| | | | |
|---|---|---|---|
| - ថ្ងៃទី ០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៧ | មករា | ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ២៣ | កុម្ភៈ | ទិវាបុណ្យមាឃបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ០៨ | មីនា | ទិវានារីអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

www.pheakdeylaw.com

- ថ្ងៃទី ១៤-១៥-១៦ មេសា ទិវាចូលឆ្នាំខ្មែរប្រពៃណីជាតិ សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ០១ ឧសភា ទិវាពលកម្មអន្តរជាតិ សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២២ ឧសភា ទិវាបុណ្យវិសាខបូជា សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២៦ ឧសភា ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០១ មិថុនា ទិវាកុមារអន្តរជាតិ សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៨ មិថុនា ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ២៤ កញ្ញា ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ០២-០៣-០៤ តុលា បុណ្យភ្ជុំបិណ្ឌ សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ២៣ តុលា ទិវាសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ៣០-៣១តុលា និង០១វិច្ឆិកា ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ០៩ វិច្ឆិកា ទិវាបុណ្យឯករាជ្យជាតិ សម្រាក ០១ ថ្ងៃ
- ថ្ងៃទី ១៥-១៦-១៧ វិច្ឆិកា ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក សម្រាក ០៣ ថ្ងៃ
- ថ្ងៃទី ១០ ធ្នូ ទិវាសិទ្ធិមនុស្សអន្តរជាតិ សម្រាក ០១ ថ្ងៃ

**មាត្រា ២.-**

ពេលវេលាឈប់សម្រាកទាំងឡាយណាដែលត្រូវចំថ្ងៃណាមួយ នៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ (សៅរ៍ ឬអាទិត្យ) ត្រូវបានអោយឈប់ចំនួន ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែ ក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នាគឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវអនុញ្ញាតអោយឈប់សម្រាកបន្ថែមជាជំនួស គឺឈប់តែ ០១ ថ្ងៃប៉ុណ្ណោះ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com